## **បត្យាប័ន២៖ បទល្មើសដែលអាចត្រូវធ្វើបត្យាប័នបាន** (Extraditable Offenses)

១. កាលណាគេនិយាយអំពីសំណើបត្យាប័ន ជាដំបូងគេនឹងពិនិត្យមើលប្រភេទបទល្មើស ដែលអាចធ្វើបត្យាប័នបាន។ បទល្មើស ត្រូវតែជាបទល្មើសដែលមានចែងក្នុងច្បាប់នៃរដ្ឋធ្វើសំណើនិងរដ្ឋទទួលសំណើ។ នេះអនុលោមតាមគោលការណ៍ double criminality។ មាត្រា៥៦៩នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា៖ *បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គល ដែលគេទាមទារនោះ ជាបទល្មើសតាមច្បាប់របស់រដ្ឋធ្វើសំណើផងនិងតាមច្បាប់កម្ពុជាផង ទោះបីជា៖ -អំពើដែលជាបទល្មើសស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នាក្តីឬ-ឈ្មោះបទល្មើស ការប្រើបច្ចេកស័ព្ទឬនិយមន័យ ឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នាក្តីឬ-ជាតុផ្សំបទល្មើសនៃច្បាប់របស់រដ្ឋធ្វើសំណើ ខុសគ្នាពីធាតុផ្សំបទល្មើស ដែលកំណត់ដោយច្បាប់កម្ពុជាក៏ដោយ ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋធ្វើសំណើ គឺជាការប្រព្រឹត្តិបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមាននៅកម្ពុជា* ។

បន្ថែមពីលើនេះ បទល្មើសដែលត្រូវចោទនិងជាកម្មវត្ថុនៃបត្យាប័ន ត្រូវតែមានទោសយ៉ាងតិច២ឆ្នាំ[1]។ សន្ធិសញ្ញាទ្វេភាគីជាមួយព្រះរាជាណាចក្រកម្ពុជា បានចែងកំណត់ដូចគ្នា គឺ២ ឆ្នាំ[2] ខណៈសន្ធិសញ្ញាខ្លះ ទម្លាក់មកត្រឹមយ៉ាងតិច១ ឆ្នាំ[3]។ បន្ថែមពីលើនេះ មានការបន្ថែម ក្នុងទម្រង់ទណ្ឌកម្មផ្សេង៖...*ដោយដាក់ពន្ធនាគារឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំងសម្រាប់រយៈពេលលើសពីមួយឆ្នាំ*...[4]។ខាងក្រោយនេះ ទំនងជាសំដៅដល់ការដាក់ទោសឃុំខ្លួនក្នុងផ្ទះ។ ពាក់ព័ន្ធរយៈពេលទោសអនុវត្តនៅសល់ ដែលអាច

---

[1] Code of Criminal Procedure, Article 571។

[2] Agreement on Extradition between the Government of the Kingdom of Cambodia and the Government of the Republic of Korea, 2009 (Cambodia-Korea Agreement 2009), Article 2(1); Treaty on Extradition between the Kingdom of Cambodia and the Socialist Republic of Viet Nam, 2013 (Cambodia-Viet Nam Treaty 2013), Article 2(1); Treaty on Extradition between the Government of the kingdom of Cambodia and the Government of the republic of France, 2015 (Cambodia-France Treaty 2015), Article 2(1)។

[3] Treaty between the Kingdom of Cambodia and the Kingdom of Thailand on Extradition, 1999, Clause 1 (1) (Cambodia-Thailand Treaty 1999); Treaty between the Kingdom of Cambodia and the People's Republic of China on Extradition, 1999 (Cambodia-China Treaty 1999), Clause 2(1); Treaty between the Kingdom of Cambodia and the Lao People's Democratic Republic on Extradition, 1999 (Cambodia-Lao Treaty 1999), clause 2(1); Treaty between the Kingdom of Cambodia and the Russian Federation on Extradition, 2017 (Cambodia-Russia Treaty 2017), Article 4 (a)។

[4] Cambodia-Thailand Treaty 1999, Clause 1។

ត្រូវបានធ្វើបត្យាប័នទៅបន្តអនុវត្តទោស បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងស្រដៀងគ្នាគឺ៦ខែ[5] ក៏ប៉ុន្តែ សន្ធិសញ្ញាខ្លះមានបន្ថែមនូវលក្ខណវិនិច្ឆ័យនៃរយៈពេលនេះ៖ *៦ខែ គិតពីកាលបរិច្ឆេទនៃសេចក្តីសម្រេចធ្វើបត្យាប័ន*[6]។

បទល្មើសត្រូវតែមានក្នុងច្បាប់នៃប្រទេសទាំងពីរ ទោះបីជាយ៉ាងនេះក្តី វាអាចជាបញ្ហា ដោយសារឈ្មោះនិងប្រភេទនៃបទល្មើស ខុសគ្នារវាងប្រទេសទាំងពីរ។ មាត្រា៥៦៩ ដកស្រង់ខាងលើ ទំនងជាផ្តោតជាសំខាន់លើជាតុផ្សំនៃបទល្មើស ទោះបីបទល្មើសនោះជាបទឧក្រិដ្ឋឬបទមជ្ឈិម និងអ្វីជាសំខាន់គឺការប្រព្រឹត្តតាមបញ្ញត្តិនៃច្បាប់ជាធរមាននៅកម្ពុជា។ ដើម្បីឲ្យកាន់តែយល់ច្បាស់ សូមពិនិត្យមើលខ្លឹមសារដកស្រង់៖ *ភាពខុសគ្នានៃវាក្យស័ព្ទច្បាប់ មិនមែនជាឧបសគ្គនៃសំណើសុំបត្យាប័នឡើយ ប្រសិនបើបទល្មើសដែលស្នើធ្វើបត្យាប័ននោះ ជាបទល្មើសព្រហ្មទណ្ឌ ដែលកំណត់ដោយច្បាប់ជាធរមានរបស់ភាគីទាំងពីរ*[7]។

សន្ធិសញ្ញាស្តីពីបត្យាប័នទាំង៧ ជាមួយរដ្ឋបរទេស បានចែងមានខ្លឹមសារស្រដៀងនឹងមាត្រា៥៦៩នេះ[8]។ ទោះបីជាយ៉ាងនេះក្តី រយៈពេលនៃទោស ១ឬ២ឆ្នាំ នៅតែជាលក្ខខណ្ឌមួយត្រូវពិចារណាផងដែរ។

បទល្មើសដែលអាចត្រូវធ្វើបត្យាប័នបាន ជាទូទៅត្រូវតែកើតមានក្នុងដែនដីនៃរដ្ឋធ្វើសំណើ ទោះបីជាយ៉ាងនេះក្តីក៏មានករណីដែលបទល្មើសត្រូវបានប្រព្រឹត្តិនៅក្រៅដែនដី បំពានច្បាប់របស់រដ្ឋធ្វើសំណើ។ កម្ពុជាអាចនឹងធ្វើបត្យាប័នបុគ្គលដែលគេទាមទារពាក់ព័ន្ធបទល្មើសនេះ លុះត្រាជននោះមានសញ្ជាតិនៃរដ្ឋធ្វើសំណើ[9] ឬមិនមែនសញ្ជាតិ បត្យាប័នអាចអនុលោមតាមឆន្ទានុសិទ្ធិ[10]។ សន្ធិសញ្ញាជាមួយសាធារណរដ្ឋកូរ៉េ មិនទាមទារសញ្ជាតិទេ អ្វីសំខាន់គឺរដ្ឋទទួលសំណើ មានច្បាប់ចែងអំពីការផ្តន្ទាទោសនៃបទល្មើសដែលប្រព្រឹត្តនៅក្រៅដែនដី[11]។

ជាចុងក្រោយ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺអនុលោមទៅតាមសន្ធិសញ្ញាឬអនុសញ្ញាដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ជាក់ស្តែង អនុសញ្ញាស្តីពីការប្រឆាំងអំពើទារុណកម្ម តម្រូវឲ្យកម្ពុជា

---

[5] Cambodia-China Treaty 1999, clause 1(2); Cambodia-Lao Treaty 1999, clause 2(2); Cambodia-Korea Agreement 2009, Article 2(2); Cambodia-Viet Nam Treaty 2013, Article 2(2); Cambodia-France Treaty 2015, article 2(2); Cambodia-Russia Treaty 2017, article 4(3)។

[6] Cambodia-Russia Treaty 2017, article 4(3)។

[7] Cambodia-Russia Treaty 2017, article 4(5)។ ករណីផ្លាស់ប្តូរលក្ខណៈនៃបទល្មើសដែលត្រូវបានចោទប្រកាន់....អាចទទួលខុសត្រូវព្រហ្មទណ្ឌឬកាត់ទោសតាមកម្រិតនៃបទល្មើសថ្មីនោះ ដោយអនុលោមតាមលក្ខខណ្ឌនៃបត្យាប័ន (Cambodia-Russia Treaty 2017, article 4.4)។... អាចបដិសេធ បើបទល្មើសត្រូវបានប្រព្រឹត្តទាំងស្រុងឬមួយផ្នែកនៅលើដែនដីរបស់ភាគីទទួលសំណើ (Cambodia-Russia Treaty 2017, article 5.2.a)។

[8]

[9] Code of Criminal Procedure, Article 572; Cambodia-Viet Nam Treaty 2013, Article 2(4)។

[10] Cambodia-Viet Nam Treaty 2013, Article 2(4)។

[11] Cambodia-Korea Agreement 2009, Article 2(5)។

(ប្រសិនមិនបានចោទប្រកាន់អ្នកប្រព្រឹត្តទារុណកម្មមានវត្តមានលើទឹកដីខ្លួន) ត្រូវបញ្ជូនឬធ្វើបត្យាប័នទៅប្រទេសផ្សេងដើម្បីទទួលរងការចោទប្រកាន់[12]។ បទប្បញ្ញត្តិនៃអនុសញ្ញានេះដដែល ចែងតម្រូវថាបទទារុណកម្មគឺជាបទល្មើស ដែលត្រូវធ្វើបត្យាប័នបាន[13]។

២. មានបទល្មើសមួយចំនួន មិនត្រូវបានចាត់ជាបទល្មើសអាចធ្វើបត្យាប័នបាន ដូចជាបទល្មើសមានលក្ខណៈនយោបាយ (political offense)។ ក្រមនីតិវិធីព្រហ្មទណ្ឌ មិនមានចែងអំពីនិយមន័យ គ្រាន់តែបង្ហាញអំពីសញ្ញាណៈ *បត្យាប័នមិនអាចធ្វើបានទេ កាលណាអំពើដែលត្រូវចោទប្រកាន់ មានលក្ខណៈនយោបាយ។ ប៉ុន្តែមិនត្រូវចាត់ទុកថាជាបទល្មើសនយោបាយទេ ចំពោះអំពើហិង្សាដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិតដល់បូរណភាពខាងរូបកាយឬដល់សេរីភាពរបស់បុគ្គល*[14]។ សន្ធិសញ្ញាស្តីពីបត្យាប័នជាមួយប្រទេសចិនបន្ថែមខ្លះថាៈ.....*ពុំរាប់បញ្ចូលនូវការធ្វើឃាតឬប៉ុនប៉ងធ្វើឃាតឬការបំពារបំពានលើរូបកាយរបស់ប្រមុខរដ្ឋឬប្រមុខរដ្ឋាភិបាលឬសមាជិកគ្រួសារនៃរដ្ឋជនទាំងនោះ*[15]។

បទល្មើសមួយប្រភេទទៀតជាបទល្មើសយោធា (military offense) ដែលមិនត្រូវចាត់ជាបទល្មើសអាចធ្វើបត្យាប័នបាន។ ក្រមនីតិវិធីព្រហ្មទណ្ឌក៏មិនបានចែងផងដែរ។ សន្ធិសញ្ញាស្តីពីបត្យាប័នបានចែង។ ទោះបីជាយ៉ាងនេះក្តី មិនមានចែងនិយមន័យ ដោយគ្រាន់តែចែងថាៈ បទល្មើសយោធា[16], បទល្មើសចែងដោយច្បាប់អាជ្ញាសឹកសុទ្ធសាធ...ពុំមែនជាបទល្មើសនៃនីតិព្រហ្មទណ្ឌ[17],បទល្មើសយោធាសុទ្ធសាធ...[18], បទល្មើសយោធាទាំងស្រុង[19]។

៣.ក្នុងសំណើបត្យាប័នដោយរដ្ឋដាក់សំណើ អាចមានបទល្មើសមួយឬច្រើន (accessory /relevant offenses)។ ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានចែង ក៏ប៉ុន្តែមានបញ្ញត្តិនៅក្នុងសន្ធិសញ្ញាស្តីពីបត្យាប័ន។

---

[12] UN General Assembly, *Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment*, United Nations, Treaty Series, vol. 1465, p. 85, 10 December 1984, https://www.refworld.org/legal/agreements/unga/1984/en/13941 [accessed 12 April 2025], Article 7។

[13] UN General Assembly, *Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment*, United Nations, Treaty Series, vol. 1465, p. 85, 10 December 1984, https://www.refworld.org/legal/agreements/unga/1984/en/13941 [accessed 12 April 2025] Article 8; Cambodia-Korea Agreement 2009, Article3(1.b); Cambodia-France Treaty 2015, Article 3(2)។

[14] Code of Criminal Procedure, Article 573; Cambodia-Viet Nam Treaty 2013, article 3(1.a); Cambodia-France Treaty 2015, article 3(a)។

[15] Cambodia-Thailand Treaty 1999, Clause 3(1); Cambodia-China Treaty 1999, clause 3(1); Cambodia-Lao Treaty 1999, clause 3(1)។

[16] Cambodia-Viet Nam Treaty 2013, Article 3(1.b)។

[17] Cambodia-Thailand Treaty 1999, Clause 3(3); Cambodia-Lao Treaty 1999, clause 3(3); Cambodia-Korea Agreement 2009, Article 3(3)។

[18] Cambodia-China Treaty 1999, clause 3(3)។

[19] Cambodia-France Treaty 2015, Article 3(d)។

បញ្ញត្តិចែងផ្តល់ឆន្ទានុសិទ្ធិដល់រដ្ឋទទួលសំណើ[20]ឲ្យតែមានលក្ខណៈគ្រប់គ្រាន់សម្រាប់ធ្វើបត្យាប័ន ដោយមិនគិតអំពីរយៈពេលនៃទោសទណ្ឌ[21]។ ក្នុងករណីមានបទល្មើសច្រើនដាច់ដោយឡែកពីគ្នា បត្យាប័ននឹងត្រូវបានផ្តល់ឲ្យចំពោះបទល្មើសក្រោយៗ ដរាបណាបុគ្គលនោះ ត្រូវបានធ្វើបត្យាប័នយ៉ាងហោចណាស់បទល្មើសមួយដែលអាចធ្វើបត្យាប័នបាន[22]។មាត្រា២(៣)នៃសន្ធិសញ្ញាជាមួយបារាំងបានចែង៖ *ប្រសិនបើសំណើសុំធ្វើបត្យាប័នចំពោះបទល្មើសច្រើនផ្សេងគ្នា ហើយដែលត្រូវបានផ្តន្ទាទោសដោយច្បាប់នៃភាគីទាំងពីរ ប៉ុន្តែបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងនោះ មិនបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី១និងទី២នោះទេ ភាគីទទួលសំណើក៏អាចផ្តល់បត្យាប័នសម្រាប់បទល្មើសនោះផងដែរ*។[23]

សូមពិនិត្យមើលអត្ថបទទីមួយស្តីពីអំពីបត្យាប័ន(ខ្លឹមសារទូទៅ)។

---

[20] Cambodia-Thailand Treaty 1999, clause 1 (4)។

[21] Cambodia-Thailand Treaty 1999, clause 1 (4); Cambodia-China Treaty 1999, clause 2(4); Cambodia-Lao Treaty 1999, clause 2(4)។

[22] Cambodia-Korea Agreement 2009, article 2(4)។

[23] Cambodia-France Treaty 2015; Cambodia-Russia Treaty 2017, Article 4(2)។